ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១៩៦

ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩

សាលដីកា

លេខ: ២០ "VIII"

ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០

# សាលដីកា
# តាងនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.លោក [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ១៩០ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ របស់ ឯកឧត្តម អគ្គព្រះរាជអាជ្ញា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៦៣ ក្រI.សវ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍ ដែលមាន ៖

-ជនជាប់ឈ្មោះ [redacted] ហ្វារី ហៅ ឃី ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ មានទីកន្លែងភូមិក សង្កាត់ច្រាំងចំរេះ២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួន [redacted]



Scanned with CamScanner

[redacted]រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted]"រ" ប្រពន្ធឈ្មោះ [redacted]"រ" មានកូនចំនួន ០១នាក់ ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

**-ឯកឧត្តម អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ (អ្នកប្តឹងសាទុក្ខ)**

**ជាប់ចោទពីបទៈ** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ភូមិក សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អំពីអង្គហេតុៈ**

កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ០៩ និង ១៥នាទី នៅចំណុចលើផ្លូវជាតិលេខ៥ ក្រុម៨ ភូមិក សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កម្លាំងអធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ បានសហការជាមួយប៉ុស្តិ៍នគរបាលច្រាំងចំរេះ២ បានបើកកិច្ចប្រតិបត្តិការចុះបង្ក្រាប ករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ឃាត់ខ្លួនបានជនជាប់ចោទឈ្មោះ [redacted] ហ្វារី ភេទប្រុស អាយុ ៣១ឆ្នាំ និងបានធ្វើការត្រួតពិនិត្យ និងឆែកឆេរលើខ្លួនជនជាប់ចោទ រកឃើញក្រាមពណ៌សថ្លាចំនួន ១ កញ្ចប់ធំ ទម្ងន់ ១២,៤៧ ក្រាម ហើយសមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួន រួមជាមួយវត្ថុតាងក្រាមពណ៌សថ្លា មកកាន់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ ដើម្បីធ្វើការសាកសួរតែម្តង ។ ក្រោយពីការសាកសួររួចមក ជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតជាបានធ្វើសកម្មភាពជួញដូរគ្រឿងញៀនពិតប្រាកដមែន ដោយគ្រឿងញៀនខ្លួនយកមកលក់នោះ គឺខ្លួនទិញជនមិនស្គាល់ឈ្មោះនៅម្តុំរោងចក្រឆ្នាំងចំនួន ០១កញ្ចប់ធំ ក្នុងតម្លៃ ១០០ អាមេរិក ហើយយកមកចែករំលែកជាកញ្ចប់ថង់ប្លាស្ទិកតូចៗ បានចំនួន៥កញ្ចប់ ដោយលក់ចេញក្នុងតម្លៃ ១០០.០០០ រៀល ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៥៨៥ "ឧ" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] ហ្វារី ហៅ យី ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរឥស្លាម ដាក់ពន្ធនាគារកំណត់ ៣ (បី) ឆ្នាំ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល បង់ចូលថវិកាជាតិ ។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចលើផ្លូវជាតិលេខ៥ ក្រុមទី៨ ភូមិក សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុចាប់យកៈ ស្រោមសំបុត្រពណ៌ស ចំនួន ០១ មានសរសេរថា ក្រាមថ្លាពណ៌ស ទម្ងន់ ១២,៤៧ ក្រាម (ដប់ពីរក្បៀសសែសិបប្រាំពីរក្រាម) ដែលដកហូតពីឈ្មោះ [redacted] ហ្វារី ត្រូវរឹបអូស ។



Scanned with CamScanner

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ៦២៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ហ្វារី ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២៥៨៥ "ខ" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៦៣ "ក្រI.សវ" ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៦២៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ហ្វារី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២-តម្កល់តាមសាលក្រមព្រហ្មទណ្ឌលេខ ២៥៨៥ "ខ" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំណុចទី១ នៃការផ្ដន្ទាទោសឈ្មោះ [redacted] ហ្វារី ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ ឆ្នាំ ០៦ ខែ ត្រូវបន្ថយមកត្រឹម ០២ឆ្នាំ ០៦ខែ វិញ ។ ចំណុចផ្សេងៗទៀតនៃសាលក្រមនេះទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ហ្វារី តាមនីតិវិធីច្បាប់ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ។

បើកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ១៩០ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៦៣ "ក្រI.សវ" ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្ដីសន្និដ្ឋានសុំថា៖

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ត្រូវបានឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ប្ដឹងសាទុក្ខ ហេតុនេះតំណាងមហាអយ្យការអមតុលាការកំពូល សូមរក្សាទុកតាមសារណារបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៦៣ "ក្រI.សវ" ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ដែលបានសម្រេចមកនេះ មិនមានលក្ខណៈត្រឹមត្រូវទេ ។



Scanned with CamScanner

តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖

១.ទទួលបណ្តឹងសាទុក្ខលេខ ១៩០ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់និងគតិច្បាប់ ។

២.បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៦៣ ក្រII "សវ" ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ចោលជាអសារបង់ ។

+ជនជាប់ចោទឈ្មោះ [redacted] ហ្វារី ឆ្លើយថា៖ ខ្ញុំបាទពិតជាបានប្រព្រឹត្តបទល្មើសប្រាកដមែន ពេលនេះខ្ញុំបាទបានដឹងខ្លួនខុស ហើយនឹងខំកសាងខ្លួនឱ្យល្អសាជាថ្មី ។

<u>សំណូមពរ:</u> សូមតុលាការតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

**១-យល់ឃើញថា** បណ្តឹងសាទុក្ខលេខ ១៩០ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**២-យល់ឃើញថា** តាមខ្លឹមសារលិខិតសារណាក្នុងបណ្តឹងសាទុក្ខលេខ ១០៤៥ ម.ហ.ក/១៩ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ដែលបានសុំឱ្យតុលាការកំពូលពិចារណាលើសាលដីកាព្រហ្មទណ្ឌលេខ ៦៣ "ក្រI សវ" ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ឡើងវិញតាមច្បាប់ ។ ចំណែកឯតំណាងមហាអយ្យការអមតុលាការកំពូល នាពេលសវនាការក៏បានធ្វើសេចក្តីសន្និដ្ឋានសុំឱ្យតុលាការកំពូលបដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៦៣ "ក្រI សវ" ខាងលើនេះ ដោយយល់ស្របទៅតាមការលើកឡើងក្នុងលិខិតសារណាក្នុងបណ្តឹងសាទុក្ខលេខ ១០៤៥ ម.ហ.ក/១៩ ដែលថា ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ គឺពុំមានលក្ខណៈត្រឹមត្រូវឡើយ ដោយហេតុថា គ្រឿងញៀនដែលដកហូតបានពីជនជាប់ចោទមានចំនួនច្រើន កម្រិតភាពសុទ្ធរហូតដល់ ៩,៧៤ ក្រាម ជាប្រភេទមេតំហ្វេតាមីន ។ ការបន្ថយទណ្ឌកម្មរបស់សាលាឧទ្ធរណ៍ លើជនជាប់ចោទមកត្រឹម ០២ឆ្នាំ ០៦ខែ ឃើញថា ស្រាលពេក នោះតុលាការកំពូលពិនិត្យឃើញថា ជាការមិនសមស្របទេ ពីព្រោះថាការដែលសាលាឧទ្ធរណ៍សម្រេចបន្ថយទណ្ឌកម្មលើជនជាប់ចោទគឺ សាលាឧទ្ធរណ៍បានយល់ឃើញត្រង់ចំណុចទី២ (ខ) និងចំណុចទី៣ នៃសំអាងហេតុរបស់ខ្លួនត្រឹមត្រូវហើយ ។

Scanned with CamScanner

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៦៣ ក្រ I “សរ” ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះ ត្រឹមត្រូវតាមគតិច្បាប់ ។

## ហេតុដូច្នេះ
## សម្រេច

១-បដិសេធបណ្តឹងសាទុក្ខលេខ ១៩០ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦៣ ក្រ I “សរ” ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ។

Scanned with CamScanner